**លេខៈ**...៩៣...សសរ

## សេចក្ដីសម្រេច

## ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ ៖** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជានាយករដ្ឋមន្ត្រីស្ដីទីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជំនួសសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋអាស៊ែបៃហ្សង់ និង សាធារណរដ្ឋបេឡារុស ចាប់ពីថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៤ រហូតដល់ពេលសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាល-រាជធានី អភិបាលគ្រប់ខេត្ត និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មេសា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល ៖**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧ - សសរ (ខ្ល)

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីរៀបចំដឹកនាំការចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ ដឹកនាំការចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ជាមួយបណ្តាប្រទេសជាដៃគូដែលមានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **វង្ស វិសុទ្ធ** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ហ៊ឹង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤- ឯកឧត្តម **កើត រិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៥- ឯកឧត្តម **ម៉ាន់ សុវសក្តិ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- លោកជំទាវ **ម៉ែន សុបនា** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៧- លោកជំទាវ **ម៉ែន មុនីមករា** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ៨- ឯកឧត្តម **សុក ស៊ីផាន់ណា** | ទីប្រឹក្សារាជរដ្ឋាភិបាល | សមាជិក |
| ៩- ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិកអចិន្ត្រៃយ៍ |
| ១០- ឯកឧត្តម **ជា វុទ្ធី** | អគ្គលេខាធិការរងនៃគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

**ប្រការ២.** គណៈកម្មការអន្តរក្រសួង មានភារកិច្ចដូចតទៅ ÷

- ធានាអនុវត្តឱ្យបានសម្រេច នូវការចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ជាមួយបណ្តាប្រទេសជាដៃគូ ជាពិសេសប្រទេសក្នុងក្របខ័ណ្ឌអាស៊ាន និងប្រទេសដែលបានស្នើសុំធ្វើការចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ សម្រេចក្របខ័ណ្ឌគោលនយោបាយនៃកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា
- ពិនិត្យ សម្រេចលើគំរូសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជា
- ពិនិត្យ សម្រេចលើកម្មវិធីចរចាកិច្ចព្រមព្រៀង ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ដើម្បីជ្រើសរើសប្រទេសជាអាទិភាពសម្រាប់ធ្វើការចរចា
- ពិនិត្យ សម្រេចយុទ្ធសាស្ត្រគោលនយោបាយសម្រាប់ការចរចាជាក់ស្តែងជាមួយប្រទេសដៃគូនីមួយៗ
- រាយការណ៍ជាប្រចាំ និងតាមការចាំបាច់ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការរាយការណ៍បន្តជូនប្រមុខរាជរដ្ឋាភិបាល នូវលទ្ធផលនៃកិច្ចចរចា និងស្នើសុំយោបល់សម្រេចលើការងារទាំងឡាយណាដែលចាំបាច់ទាក់ទងនឹងគោលនយោបាយ
- ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ និងតាមការចាំបាច់ក្នុងករណីមានភារកិច្ចបន្ទាន់ ។

**ប្រការ៣.** គណៈកម្មការអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើរាល់លិខិតស្នាមផ្លូវការ ដោយមានការឯកភាពពីគណៈកម្មការនេះ ទាក់ទងនឹងការចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា។

**ប្រការ៤.** គណៈកម្មការអន្តរក្រសួងមានក្រុមការងារបច្ចេកទេសជាសេនាធិការ ដើម្បីពិនិត្យសិក្សាលើកិច្ចការពន្ធដារជាតិ និងអន្តរជាតិ ព្រមទាំងរៀបចំកម្មវិធីចរចាក្នុងកម្រិតបច្ចេកទេស សម្រាប់កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ដែលមានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | ប្រធាន |
| ២- ឯកឧត្តម **ផៃ សុខខេង** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- ឯកឧត្តម **ម៉ែន ពេជ្ជសាលី** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៤- ឯកឧត្តម **ពេជ ឫទ្ធី** | អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- ឯកឧត្តម **ថេង បញ្ញាធន** | អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការ នៃក្រសួងផែនការ | សមាជិក |
| ៦- ឯកឧត្តម **ជា វុទ្ធី** | អគ្គលេខាធិការរងនៃគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៧- ឯកឧត្តម **កែវ ស៊ីវន** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ៨- ឯកឧត្តម **អ៊ុំ សីហា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩- ឯកឧត្តម **ទ៉ាន់ ពុទ្ធិពល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១០- ឯកឧត្តម **ហេង សុខណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១១- ឯកឧត្តម **កែន សម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១២- លោក **កែ វិសិដ្ឋ** | ប្រធាននាយកដ្ឋាននីតិកម្មនិងកុងស៊ុល នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៣- លោក **អេង រតនា** | ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៤- លោក **ចែម វាសនា** | ប្រធាននាយកដ្ឋានត្រួតពិនិត្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |

| | | |
|---|---|---|
| ១៥- លោក **ស្រ៊ុន អង្គរ៉ែន** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៦- លោក **គីម ទិចិត្រ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៧- លោក **សែម សាខន** | អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៨- លោក **ជូ ស្រ៊ុន** | អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៩- លោក **គង់ សុខហេង** | អនុប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២០- លោក **អ៊ុក សុមេធា** | ប្រធានការិយាល័យពន្ធអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ | លេខាធិការ |
| ២១- លោក **សុខ ឆឿង** | ប្រធានការិយាល័យច្បាប់ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២២- លោក **ជួរ សៃ** | ប្រធានការិយាល័យសវនកម្មទី៧ និងរដ្ឋបាល នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៣- លោក **ម៉ូ សណ្ដាប់** | អនុប្រធានការិយាល័យសវនកម្មទី២ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៤- លោក **ហេង សុធី** | អនុប្រធានការិយាល័យសវនកម្មទី១ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៥- លោកស្រី **ម៉ិត សោភា** | មន្ត្រីការិយាល័យពន្ធអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៦- កញ្ញា **ស៊ីន សុខពៅ** | មន្ត្រីការិយាល័យច្បាប់នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៧- លោក **ស៊ឹម សូលីន** | មន្ត្រីការិយាល័យពន្ធអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ | លេខាធិការ |
| ២៨- កញ្ញា **យុង សោភា** | មន្ត្រីការិយាល័យពន្ធអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ | លេខាធិការ |

**ប្រការ៥.-** ក្រុមការងារបច្ចេកទេស មានភារកិច្ចដូចតទៅ÷

- រៀបចំកិច្ចការផ្នែកបច្ចេកទេសនៃកិច្ចព្រមព្រៀងស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា ជាមួយបណ្ដាប្រទេសជាដៃគូ ដើម្បីដាក់ជូនគណៈកម្មការអន្តរក្រសួង សម្រេច

- រៀបចំគំរូសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជា ជាមួយបណ្តាប្រទេសជាដៃគូ ដើម្បីដាក់ជូនគណៈកម្មការអន្តរក្រសួង ពិនិត្យ សម្រេច
- រៀបចំកម្មវិធីចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ដើម្បីជ្រើសរើសប្រទេសជាអាទិភាពសម្រាប់ធ្វើការចរចា និងដាក់ជូនគណៈកម្មការអន្តរក្រសួង សម្រេច
- រៀបចំយុទ្ធសាស្ត្រគោលនយោបាយសម្រាប់ការចរចាជាក់ស្តែង ជាមួយប្រទេសជាដៃគូនីមួយៗ ដើម្បីដាក់ជូនគណៈកម្មការអន្តរក្រសួង ពិនិត្យ សម្រេច
- រៀបចំរបៀបវារៈ និងឯកសារពាក់ព័ន្ធសម្រាប់កិច្ចប្រជុំក្រុមការងារ និងភារកិច្ចផ្សេងទៀតដែលចាំបាច់ក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស ដើម្បីដាក់ជូនគណៈកម្មការអន្តរក្រសួង ពិនិត្យ សម្រេច
- រៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមការងារ និងរៀបចំឯកសារផ្សេងៗទៀត ដើម្បីដាក់ជូនគណៈកម្មការអន្តរក្រសួង ពិនិត្យសម្រេច និងរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំគម្រោងថវិកាចំណាយសម្រាប់ដំណើរការនៃកិច្ចចរចាទៅតាមកម្មវិធីនីមួយៗ និងស្នើសុំការសម្រេចពីគណៈកម្មការអន្តរក្រសួង
- ទទួលអនុវត្តបន្តនូវភារកិច្ចផ្សេងៗទៀត ដែលស្នើដោយគណៈកម្មការអន្តរក្រសួង
- តាមដាន និងធ្វើរបាយការណ៍ប្រចាំត្រីមាស ឬឆមាស ឬប្រចាំឆ្នាំស្តីពីវឌ្ឍនភាពការងារជូនគណៈកម្មការអន្តរក្រសួង
- ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង និងតាមការចាំបាច់ក្នុងករណីមានភារកិច្ចបន្ទាន់។

**ប្រការ៦.** ក្រុមការងារបច្ចេកទេស មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋានពន្ធដារ លើរាល់លិខិតស្នាមផ្លូវការទាក់ទងនឹងការចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ដែលឯកភាពដោយក្រុមការងារបច្ចេកទេសនេះ ។

**ប្រការ៧.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឆ្នាំទី១៤ លេខ ៣២  សប្តាហ៍ទី៤  ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៤  រាជកិច្ច ទំព័រ ៣៨៥៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ០២ សរណន

**សារាចរណែនាំ**

**ស្តីពី**

**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥**

## I. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា៣ដំណាក់កាលគឺ (១) **ដំណាក់កាលទី១**: ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាពីខែមីនា ដល់ខែឧសភា (២) **ដំណាក់កាលទី២**: ការរៀបចំកញ្ចប់ថវិកាពីខែមិថុនា ដល់ខែកញ្ញា និង (៣) **ដំណាក់កាលទី៣**: ការអនុម័តថវិកាពីខែតុលា ដល់ខែធ្នូ។ ដើម្បីជាមូលដ្ឋាននៃការរៀបចំផែនការយុទ្ធ-សាស្ត្រថវិកាឆ្នាំ២០១៥ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំរួចហើយនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។ ជាបន្តទៅទៀត រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ដើម្បីធ្វើជាមគ្គុទ្ទេសក៍សម្រាប់ណែនាំ និងជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ របស់គ្រប់ក្រសួង-ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ដែលជារដ្ឋបាលថ្នាក់ជាតិ។ ដោយឡែក ចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំដោយឡែកមួយទៀត ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។

២- ផែនការយុទ្ធសាស្ត្រថវិកា ជាផែនការថវិការយៈពេលមធ្យម (៣ឆ្នាំរំកិល) ដែលឆ្លុះបញ្ចាំងពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពដើម្បីអនុវត្ត ព្រមទាំងសូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្ត។ ផែនការយុទ្ធសាស្ត្រថវិកា គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ (១) ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២) បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣) ជាមូលដ្ឋានសម្រាប់ពន្យល់និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤) ធានានិរន្តរភាពនៃកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព និង(៥) ជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាពក្នុងការកំណត់កញ្ចប់ និងការវិភាជថវិកា។ នៅក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍យ៉ាងសំខាន់សម្រាប់ការបង្កើតឲ្យមានយន្តការកាន់តែមានភាពប្រាកដនិយម ក្នុងការជួយបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការប្រើប្រាស់ថវិកា តាមរយៈការជួយតម្រង់ និងជំរុញការវិភាជថវិកាឲ្យចំទិសដៅ បម្រើឲ្យសកម្មភាពអាទិភាព និងចំតម្រូវការជាក់ស្តែង សំដៅធ្វើឲ្យរាល់ចំណាយរបស់ក្រសួង-ស្ថាប័ន ទាំងចំណាយរបស់រដ្ឋបាលកណ្តាល ទាំងចំណាយរបស់មន្ទីរជំនាញរាជធានី-ខេត្ត បម្រើឲ្យគោលនយោបាយជាយុទ្ធសាស្ត្រ និងអាទិភាពរបស់ខ្លួន ក៏ដូចជាគោលនយោបាយជាយុទ្ធសាស្ត្រ និងអាទិភាពរបស់

វិស័យនីមួយៗ សម្រាប់រួមចំណែកសម្រេចឲ្យបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្រ្តថវិកា គឺជាកម្មវត្ថុនៃការងារដែលចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ក្រសួងមួយត្រូវមានផែនការយុទ្ធសាស្រ្តថវិកាតែមួយ ដែលគ្របដណ្តប់ទាំងថវិការបស់រដ្ឋបាលកណ្តាល និងរបស់មន្ទីររាជធានី-ខេត្តចំណុះក្រសួងនោះ។

៣- កត្តាគន្លឹះមិនអាចខ្វះបានដើម្បីឲ្យផែនការយុទ្ធសាស្រ្តថវិកា អាចក្លាយជាឧបករណ៍ និងយន្តការដែលមានប្រសិទ្ធភាពជាក់ស្តែង ក្នុងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ក្នុងការវិភាជ និងគ្រប់គ្រងថវិកា គឺការធ្វើឲ្យមានសមាហរណកម្មពិតប្រាកដ រវាងថវិកាចរន្តនិងថវិកាមូលធន រវាងថវិកាជាតិនិងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ឲ្យទៅជាថវិកាមួយឯកភាព និងគ្រប់ជ្រុងជ្រោយ។ នៅក្នុងន័យនេះ ក្រសួង-ស្ថាប័ននីមួយៗចាំបាច់ត្រូវធ្វើយ៉ាងណាឲ្យក្រុមការងារថវិការបស់ខ្លួន ដែលមានសមាសភាពមកពីនាយកដ្ឋានហិរញ្ញវត្ថុឬ/និងគណនេយ្យ នាយកដ្ឋានផែនការ អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោង មានដំណើរការដោយសកម្មមានប្រសិទ្ធភាព និងមានការទទួលខុសត្រូវ។ តួនាទីក្រុមការងារថវិកា ត្រូវខិតខំធ្វើម៉េចឲ្យធនធានទាំងអស់ក៏ដូចជាសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្រ្តថវិកា សំដៅធ្វើយ៉ាងណាឲ្យការវិភាជថវិកាមានប្រសិទ្ធភាព (ចំសេចក្តីត្រូវការពិតប្រាកដ) និងមានតុល្យភាពរវាងគោលបំណងគោលនយោបាយ និងរវាងកម្មវិធី នៃផែនការយុទ្ធសាស្រ្តថវិការបស់ក្រសួង-ស្ថាប័ន។

៤- ចាប់តាំងពីត្រូវបានដាក់ឲ្យអនុវត្តជាលើកដំបូងក្នុងឆ្នាំ២០០៨ មកទល់នឹងពេលនេះ ការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ជារួម ត្រូវបានកែលម្អជាលំដាប់។ ទោះជាយ៉ាងនេះក្តី ការងារនេះនៅតែមិនទាន់បានដល់កម្រិតដែលរាជរដ្ឋាភិបាលចង់បាននៅឡើយទេ។ លើសពីនេះ គួររំលឹកថា នៅពេលដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងឈានដល់ដំណាក់កាលអនុវត្តបញ្ចប់ដំណាក់កាលទី២ (ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ) និងត្រៀមអនុវត្តដំណាក់កាលទី៣ (ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ) និងទី៤ (ការបង្កើនគណនេយ្យភាពសមិទ្ធិកម្ម) នៅមុនដំណាច់នីតិកាលទី៤ រាជរដ្ឋាភិបាលបានដាក់ចេញ "ទិសដៅជាយុទ្ធសាស្រ្តនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០" ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗ ពីការផ្តោតលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធថវិកាថ្មី គឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ។ នៅលើមាគ៌ានៃកំណែទម្រង់នេះ ឆ្នាំ២០១៥ នឹងមានក្រសួងចំនួន ១០ ត្រូវក្លាយទៅជាក្រសួងដែលត្រូវអនុវត្ត "ថវិកាកម្មវិធីពេញលេញ" ដោយមានការវិភាជថវិកានិងការធ្វើប្រតិភូកម្មសិទ្ធិអំណាច ក្នុងការអនុវត្តចំណាយមួយចំនួន រហូតដល់កម្រិតអគ្គនាយកដ្ឋាន ឬអាចដល់នាយកដ្ឋាន ហៅថា "អង្គភាពថវិកា"។ ក្រសួងទាំង ១០ រួមមាន ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកិច្ចការនារី, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់, និងក្រសួងយុត្តិធម៌។ ជាមួយគ្នានឹងការដាក់ឲ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងការបង្កើតឲ្យមានអង្គភាពថវិកាសម្រាប់ការគ្រប់គ្រងថវិកានៅក្រសួងទាំង១០ ចាប់ពីឆ្នាំ ២០១៥ទៅ "ការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា (FMIS)" នឹងត្រូវដាក់ឲ្យអនុវត្តជាបណ្តើរៗដែរ ដោយចាប់ផ្តើមចេញពីអគ្គនាយកដ្ឋានរតនាគារជាតិ ហើយដើម្បីគាំទ្រដល់ការងារទាំងអស់នេះ និងដើម្បីឲ្យកាន់តែស្របតាមបទដ្ឋានអន្តរជាតិ "មាតិកាថវិកាថ្មី" ក៏នឹងត្រូវដាក់ឲ្យអនុវត្តក្នុងពេលដំណាលគ្នានេះដែរ។ ជារួម អាចនិយាយបានថា ការរៀបចំថវិកាឆ្នាំ ២០១៥ គឺជាការចាប់ផ្តើមនៃដំណើរឈានឆ្ពោះទៅរកប្រព័ន្ធថវិកាថ្មី ហើយក៏អាចចាត់ទុកថាជារបត់ថ្មីនៃការងារគ្រប់គ្រងថវិកា ជាពិសេសការងាររៀបចំថវិកា។ នៅក្នុងបរិការណ៍នេះ ដើម្បីឲ្យថវិកាអាចជាឧបករណ៍ដ៏មានប្រសិទ្ធភាពពិតប្រាកដ សម្រាប់រួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្រ្តចតុកោណដំណាក់កាល ទី៣ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ឲ្យបានជោគជ័យ ក្រសួង-ស្ថាប័ន

ចាំបាច់ត្រូវយកចិត្តទុកដាក់លើកកម្ពស់គុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឲ្យបានប្រសើរថែមទៀត។ ក្នុងន័យនេះ ដើម្បីជាមគ្គុទេសក៍ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន ដូចតទៅ៖

**II. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

៥-ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ មានតួនាទីផ្តល់ជាទស្សនៈវិស័យទូលំទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់ពីការរំពឹងទុកផ្នែកគោលនយោបាយ ដែលរាជរដ្ឋាភិបាលមានលទ្ធភាពអាចនឹងសម្រេចបាន ហើយតាមរយៈនេះ បង្កើតបានជាលំហគោលនយោបាយរួម សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាចកំណត់ទិសដៅការងាររយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ទន្ទឹមនឹងនេះ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ក៏កំណត់អំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល ។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកាគឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះគឺមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីជានាប្រសិទ្ធភាព និងភាពប្រាកដប្រជានៃការរៀបចំថវិកា។ នៅក្នុងន័យនេះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូល នៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម៖

**ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច**

៦-តាមការព្យាករដោយប្រយ័ត្នប្រយែង និងដោយផ្អែកលើនិន្នាការសេដ្ឋកិច្ចដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៤ នេះ អាចនឹងបន្តសម្រេចបាន៧% ដូចដែលបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ ចំពោះកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៥ វិញ តាមការព្យាករ អាចនឹងបន្តសម្រេចបានក្នុងរង្វង់៧%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៣,៩% វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ៨,៧% វិស័យវាយនភណ្ឌនឹងអាចកើនឡើងប្រមាណ៨,២% វិស័យសេវាកម្មអាចនឹងសម្រេចបានកំណើនប្រមាណ ៧%។

៧-អតិផរណានៅឆ្នាំ២០១៤ តាមការប៉ាន់ស្មាន នឹងមានកម្រិត៣,៥% គឺដូចទៅនឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ហើយនឹងបន្តរក្សាកម្រិតថេរក្នុងកម្រិត៣,៥% ដដែល ក្នុងឆ្នាំ២០១៥។

៨-អត្រាប្តូរប្រាក់នៅឆ្នាំ២០១៤ តាមការប៉ាន់ស្មាន នឹងមានតម្លៃជាមធ្យម៤ ០៥០រៀល ក្នុង១ដុល្លារអាមេរិក ដូចគ្នានឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ តាមការព្យាករ នៅឆ្នាំ២០១៥ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំនឹងនៅតែមានតម្លៃ៤ ០៥០រៀល ក្នុង១ដុល្លារអាមេរិក ដែលកម្មវត្ថុចម្បងគឺដើម្បីរក្សាតុល្យភាពនៃការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ការប្រកួតប្រជែងជាមួយដៃគូពាណិជ្ជកម្មលើពិភពលោក និងការបង្កើនជំនឿទៅលើការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។

៩- ឱនភាពគណនីចរន្តនៅឆ្នាំ២០១៤ តាមការប៉ាន់ស្មាន នឹងមានកម្រិត ៩,២៩% នៃផសស ដូចគ្នានឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ គឺបានប្រសើរឡើង ធៀបនឹងឆ្នាំ២០១៣ ដែលមានកម្រិត ៩,៤៥% នៃផសស។ ទន្ទឹមនេះ តាមការព្យាករនៅឆ្នាំ២០១៥ ឱនភាពគណនីចរន្ត នឹងបន្តធ្លាក់ចុះទៀតមកត្រឹម ៩,១៤% នៃផសស។ និន្នាការនៃការធ្លាក់ចុះឱនភាពគណនីចរន្ត ដោយសារសមត្ថភាពនាំចេញ

របស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសការនាំចូលជាបណ្តើរៗ។

**ខ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

១០-ដោយផ្អែកលើមូលដ្ឋាននៃ "យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣" និង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨" គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៥-២០១៧ ត្រូវបានកំណត់គោលដៅសំខាន់ៗដូចតទៅ៖

- បន្តសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព។
- ធានាការអនុវត្តគោលនយោបាយដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន។
- ធានាបន្តអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាលឲ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កា រួមមាន កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ កំណែទម្រង់ដីធ្លី និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។
- បន្តអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។
- ធានាការចាប់ផ្តើមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម។
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ។
- ពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឲ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព។
- លើកកម្ពស់គុណភាព ពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ។
- ធានាបន្តការពារឲ្យបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ។

១១-ដើម្បីសម្រេចបានតាមគោលដៅខាងលើ គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៥-២០១៧ មានគោលដៅបង្កើនការប្រមូលចំណូលក្នុងប្រទេសឲ្យបានប្រមាណ ០,៥%នៃផសស ក្នុង១ឆ្នាំ ហើយពង្រឹងវិន័យនិងបង្កើនគុណភាពចំណាយ តាមរយៈការធ្វើវិចារណកម្ម និងការធ្វើអាទិភាវូបនីយកម្មចំណាយ ក្នុងគោលដៅរក្សាអតិរេកថវិកាចរន្តឲ្យបានក្នុងរង្វង់៣%នៃផសស និងឱនភាពថវិកាសរុបឲ្យស្ថិតក្រោម៥%នៃផសស។ ដើម្បីសម្រេចគោលដៅនេះថវិកាឆ្នាំ២០១៥ ត្រូវបានកំណត់ដូចខាងក្រោម៖

- ចំណូលសរុបក្នុងប្រទេសសម្រាប់ឆ្នាំ២០១៥ ត្រូវសម្រេចឲ្យបាន១៥,៩៥%នៃផសស ក្នុងនោះ ចំណូលក្នុងប្រទេសថ្នាក់ជាតិ ត្រូវសម្រេចឲ្យបាន១៥,០៥%នៃផសស។ ចំណូលចរន្តថ្នាក់ជាតិ ត្រូវសម្រេចឲ្យបាន១៤,៨៧%នៃផសស គឺចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវសម្រេចឲ្យបាន ៧,០៨%នៃផសស ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឲ្យបាន៥,៤១% នៃផសស ចំណូលសារពើពន្ធផ្សេងៗទៀតត្រូវសម្រេចឲ្យបាន០,៤%នៃផសស និងចំណូល

មិនមែនសារពើពន្ធត្រូវសម្រេចឲ្យបាន១,៩៨%នៃផសស។ ចំណូលមូលធនក្នុងប្រទេសត្រូវសម្រេចឲ្យបាន ០,១៨% នៃផសស។

- ចំណាយសរុបសម្រាប់ឆ្នាំ២០១៥ ត្រូវរក្សាឲ្យនៅត្រឹម២០,៩១%នៃផសស ដោយចំណាយចរន្តនឹងកម្រិតត្រឹម១៣%នៃផសស ដោយផ្តោតអាទិភាពលើការបង្កើនចំណែកបៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឲ្យបាន ៤៧% នៃចំណាយចរន្តសរុប ឬស្មើប្រមាណ ៦,១១%នៃផសស។ ជាមួយគ្នានេះដែរ ចំណាយមូលធននឹងរក្សាត្រឹម៧,៩១%នៃផសស ដើម្បីជាមូលដ្ឋានសម្រាប់ការវិនិយោគទ្រទ្រង់កំណើន។

១២-ដើម្បីធានាឲ្យគោលដៅចំណូលសរុបខាងលើអាចសម្រេចបានជោគជ័យ រាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មី ឬតម្លើងពន្ធបន្ថែមដល់ប្រជាជន និងធុរជននោះទេ គឺរាជរដ្ឋាភិបាលនឹងផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ទាំងសម្រាប់រយៈពេលខ្លី មធ្យម និងវែង ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើគេចពន្ធ និងការគេចវេះពន្ធគ្រប់រូបភាពឲ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ និងផ្នែកពន្ធដារ ព្រមទាំងផ្នែកមិនមែនសារពើពន្ធ ជាពិសេសតាមរយៈការដាក់ឲ្យអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ក្នុងនោះក្របខ័ណ្ឌនៃវិធានការ សំខាន់ៗ ដូចតទៅ÷

**១៣-វិធានការផ្នែកចំណូលគយ និងរដ្ឋាករ មានដូចខាងក្រោម៖**

- ពង្រឹងនីតិវិធីត្រួតពិនិត្យ និងបញ្ចេញទំនិញពីគយ តាមរយៈការពង្រឹងយន្តការគ្រប់គ្រងឯកសារនាំចេញនាំចូល ការកំណត់ទិន្នន័យអប្បបរមាក្នុងវិក័យប័ត្រទំនិញ ពង្រឹងប្រសិទ្ធភាពនៃសង្គតិភាព និងអនុលោមភាពឯកសារទំនិញ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយស្របតាមតម្លៃទិញលក់ពិត ពង្រីកនិងបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងហានិភ័យនិងធុរជន ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់ និងពង្រីកសវនកម្មក្រោយការបញ្ចេញទំនិញពីគយ។
- ពង្រឹងយន្តការឆ្លងកាត់ ដោយផ្តោតជាសំខាន់លើការបង្ក្រាបអំពើគេចពន្ធ ក្នុងនោះរួមមានការបន្តអនុវត្តផែនការសកម្មភាពរយៈពេល៦០ថ្ងៃ។
  បន្តឃ្លាំមើលអនុលោមភាពនៃទំនិញក្រោមរបបអនុគ្រោះ ដាក់អនុវត្តតែមសម្គាល់យានយន្តនាំចូលរួចពន្ធ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យយានយន្ត រៀបចំសន្និធិគយបណ្តោះអាសន្ននៅតាមការិយាល័យគយព្រំដែនគោក។
- ពង្រឹងយន្តការគាំទ្រ ដោយផ្តោតជាសំខាន់លើការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអាស៊ីគូដា ប្រព័ន្ធបញ្ជរជាតិតែមួយ និងយន្តការសហប្រតិបត្តិការរវាងគយនិងវិស័យឯកជន។
- កែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន ដូចជា បារី និងភេសជ្ជៈមានជាតិអាល់កុល រថយន្ត គ្រឿងអេឡិចត្រូចនិច (ទូរស័ព្ទ)។
- ការអនុវត្តតឹងរ៉ឹងនូវការប្រើប្រាស់តែមលើផលិតផលជាប់អាករពិសេស និងសនិទានកម្មទំនិញនាំចូល ដែលជាប់អាករពិសេស។
- ចាប់ផ្តើមសិក្សា និងពិនិត្យឡើងវិញ ដើម្បីធ្វើវិចារណកម្មបន្ទាត់អត្រាពន្ធនាំចូល និងស្វែងរកវិធីសាស្ត្រក្នុងការកំណត់ថ្លៃមូលគិតពន្ធ ដែលមានលក្ខណៈជាក់ស្តែងនិយម។
- ពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកំណែទម្រង់គយ និងការគ្រប់គ្រងធនធានមនុស្ស ព្រមទាំងមុខងារសវនកម្មផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

**១៤-វិធានការផ្នែកចំណូលពន្ធដារ មានដូចខាងក្រោម៖**

- អនុវត្តផែនការសកម្មភាព និងអាទិភាពដែលបានរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ ដូចជា ពិនិត្យឡើងវិញលើអនុក្រឹត្យស្តីពី ការរៀបចំសេចក្តីព្រាងប្រកាសស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ សេចក្តីព្រាងប្រកាសស្តីពីវិធានការ និងនីតិវិធីបណ្តឹងតវ៉ា រៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រង និងប្រមូលបំណុលពន្ធ សេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌របស់មន្ត្រីពន្ធដារ ព្រមទាំងរៀបចំផែនការសកម្មភាព និងអាទិភាពក្នុងការរៀបចំច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត។
- កំណត់គោលដៅប្រមូលបំណុលពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ។
- បន្តការងារលុបចោលការចុះបញ្ជី (De-registration) ចំពោះសហគ្រាសដែលបាត់ខ្លួន មិនដាក់លិខិតប្រកាស និងគ្មានសកម្មភាព ដើម្បីគ្រប់គ្រងបញ្ជីអ្នកជាប់ពន្ធចរន្ត និងធ្វើឲ្យសុក្រឹតនូវបញ្ជីអ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មពិតប្រាកដ។
- ផ្តល់ធនធាននិងមធ្យោបាយឲ្យបានគ្រប់គ្រាន់ ដល់ការងារផ្តល់សេវាអ្នកជាប់ពន្ធនៅអង្គភាពមូលដ្ឋាន និងថ្នាក់កណ្តាល នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធានាការអនុវត្តគោលដៅយុទ្ធ-សាស្ត្រពាក់ព័ន្ធនឹងការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយភាពជោគជ័យ។
- កែលម្អវិធីសាស្ត្រកំណត់ហានិភ័យដែលមានស្រាប់ និងរៀបចំសារាចរណែនាំសម្រាប់ដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដាររួមមួយ ដើម្បីចុះធ្វើសវនកម្ម និងចៀសវាងការធ្វើសវនកម្មត្រួតជាន់គ្នា។
- រៀបចំការកត់ត្រាលទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញ ដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិ-ភ័យមុនពេលចុះសវនកម្មកន្លងមក សម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យនៅពេលក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ (ដូចជាគោរពច្បាប់ កំហុសអចេតនា អនុវត្តច្បាប់ខុស ប្រកាសប្រាក់ពន្ធខ្វះ គេចវេះពន្ធធ្ងន់ធ្ងរ)។
- ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រជាប្រព័ន្ធ ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា។
- កែសម្រួលអត្រាអាករពិសេស និងមូលដ្ឋានគិតអាករពិសេស លើមុខទំនិញមួយចំនួន ដូចជា បារី និង គេសជ្ជៈមានជាតិអាល់កុល។
- ជំរុញការអនុម័តសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត។

**១៥-វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម៖**

- បន្តស្រាវជ្រាវ និងកំណត់ឲ្យបានច្បាស់លាស់នូវបំណុលមិនមែនសារពើពន្ធគ្រប់ប្រភេទ ហើយបន្តជំរុញការអនុវត្តនូវផែនការតឹងទារបំណុលទាំងអស់នោះ ដោយម៉ត់ចត់ជាប្រចាំ និងសង្គតិ-ភាព។
- យកចិត្តទុកដាក់ជាពិសេស ទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលពីទិដ្ឋាការ ចំណូលពីការជួលពេងចក្រ សហគ្រាស និងទ្រព្យ សម្បត្តិរដ្ឋផ្សេងៗទៀត។
- ពិនិត្យ និងស្រាវជ្រាវឡើងវិញពីការយកកំរៃ និងសួយសារ ក្នុងវិស័យរ៉ែ ប្រេងកាត និងឧស្ម័ន។
- បង្កើតយន្តការតាមដានការអនុវត្តកិច្ចសន្យារុករក ឬការធ្វើអាជីវកម្មរ៉ែ រួមបញ្ចូលទាំងការបូមខ្សាច់ ការកាយយកថ្ម និងការកកាយអាចម៍ដី ជាដើម ដើម្បីជាមូលដ្ឋានច្បាស់លាស់ក្នុងការប្រមូលចំណូល។

- បន្តពង្រឹង និងជំរុញឲ្យបានជោគជ័យនូវវិធានការកែទម្រង់ការគ្រប់គ្រងកំរៃសេវារដ្ឋបាលរបស់រដ្ឋដែលទើបត្រូវបានដាក់ចេញក្នុងពេលថ្មីកន្លងមក។
- សិក្សាកែប្រែកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន ដែលទទួលសិទ្ធិគ្រប់គ្រងសកម្មភាពរបស់អាកាសយានដ្ឋាន និងសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា ដើម្បីទទួលបានផលប្រយោជន៍សមស្របជូនរាជរដ្ឋាភិបាល នៅក្នុងពេលដែលចំនួនអ្នកទេសចរណ៍បន្តកើនឡើង។
- ជំរុញការរៀបចំ និងដាក់ឲ្យដំណើរការមជ្ឈមណ្ឌលព័ត៌មានទូរគមនាគមន៍ (DMC) ឲ្យបានឆាប់ ដើម្បីកៀរគរចំណូលពីវិស័យទូរគមនាគមន៍។
- បង្កើតយន្តការអន្តរក្រសួងដើម្បីដោះស្រាយបញ្ហាដីសម្បទានសេដ្ឋកិច្ច និងប្រមូលចំណូលថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច។
- ពិនិត្យទៅលើសមត្ថភាព ក្របខ័ណ្ឌគុណវឌ្ឍន៍ និងគតិយុត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីបញ្ចូលគ្រឹះស្ថានមួយចំនួន ទៅជាសហគ្រាសសាធារណៈ។
- ពិនិត្យ និងកែប្រែកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋមួយចំនួន ដែលមិនបានផ្តល់ផលប្រយោជន៍សមរម្យដល់ភាគីរាជរដ្ឋាភិបាល ។
- ជំរុញការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ និងការអនុម័តច្បាប់នេះ។
- បន្តពង្រឹងអនុលោមភាពនៃការប្រើប្រាស់សៀវភៅបន្ទុក និងបង្កាន់ដៃបង់ប្រាក់ដើម្បីពង្រឹងការប្រមូលពីសេវាសាធារណៈ។
- ជំរុញឲ្យមានការស្រាវជ្រាវប្រភពចំណូលថ្មី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបង្កើនចំណូលបង់ចូលថវិការដ្ឋ។ សម្រាប់ថ្នាក់ក្រោមជាតិ ជំរុញការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ពង្រឹងការងារសវនកម្មលើការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ។

១៣-ចំពោះផ្នែកចំណាយវិញ រាជរដ្ឋាភិបាលបានកំណត់អាទិភាពគោលនយោបាយ ព្រមទាំងវិធានការដូចខាងក្រោម៖

- បន្តអនុវត្តការបង្កើនប្រាក់បៀវត្ស ក្នុងល្បឿន និងទំហំ ដែលអាចរក្សាបានចីរភាពនៃថវិកា និងជានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយឈរលើគោលការណ៍ប្រសិទ្ធភាព សមធម៌ និងសង្គតិភាពក្នុងគោលដៅដើម្បីកែលម្អ និងពង្រឹងគុណភាព សេវាសាធារណៈឲ្យបានកាន់តែប្រសើរ។
- បង្កើនប្រសិទ្ធភាព និងតម្លាភាពនៃចំណាយសាធារណៈឲ្យប្រសើរជាងមុន ចំទិសដៅអាទិភាព និង ឲ្យបានច្រើនជាងមុន តាមរយៈការធានាឲ្យថវិកាមានការផ្សារភ្ជាប់កាន់តែខ្លាំងឡើងជាមួយនឹងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេសតាមរយៈការដាក់ឲ្យអនុវត្តសាកល្បងថវិកាតាមកម្មវិធីពេញលេញចំនួន ១០ ក្រសួង។
- បន្តរក្សាអាទិភាព និងវិចារណកម្មនៃគោលនយោបាយចំណាយដល់វិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាព កសិកម្ម ដីធ្លី និងអភិវឌ្ឍន៍ជនបទ ទឹកស្អាត សាលារៀន មន្ទីរពេទ្យ ។ល។
- បន្តការវិនិយោគលើការពង្រីក ការកែលម្អ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព អគ្គិសនី ។ល។
- ជំរុញការលើកទឹកចិត្តក្នុងការងារស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ។

- ផ្តោតការយកចិត្តទុកដាក់ក្នុងការវិនិយោគរដ្ឋក្នុងវិស័យកសិកម្ម និងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និងជំរុញការកែច្នៃ និងនាំចេញកសិផល ជាពិសេសក្នុងវិស័យចិញ្ចឹមសត្វ។
- ធ្វើវិចារណកម្មចំណាយ ដើម្បីកាត់បន្ថយឱនភាពថវិកា ឲ្យមកត្រឹមកម្រិតមួយសមរម្យ ស្របតាមគោលការណ៍អន្តរជាតិ និងតំបន់។
- រឹតបន្តឹង និងសន្សំសំចៃ សំដៅបង្កើន "លំហថវិកា" សម្រាប់ដោះស្រាយសេចក្តីត្រូវការបន្ទាន់ក្នុងការងារអភិវឌ្ឍ ក៏ដូចជាសម្រាប់ត្រៀមជាយថាហេតុចាំបាច់ផ្សេងទៀត ពិសេសត្រៀមដោះស្រាយទប់ទល់នឹងវិបត្តិ។
- បន្តលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពក្នុងការគ្រប់គ្រង និងការចាត់ចែងចំណាយចាប់តាំងពីដំណាក់កាលនៃការរៀបចំ ការអនុវត្ត ការតាមដាន ការត្រួតពិនិត្យ និងសវនកម្ម លើលទ្ធផលនៃការអនុវត្តថវិកា។
- បន្តរឹតត្បៀតចំណាយចរន្ត ជាពិសេសការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ជៀសវាងបេសកកម្មបរទេស ឬការរៀបចំប្រជុំនៅក្នុងប្រទេសដែលពុំសូវចាំបាច់ បន្ថយការទិញសម្ភារៈប្រណិត ការទិញសម្ភារៈថ្មី និងការបោះពុម្ពដែលមិនសូវចាំបាច់ និងមានវិធានការម៉ឺងម៉ាត់ក្នុងកិច្ចលទ្ធកម្មសាធារណៈ។
- អនុវត្តឲ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ។
- ពង្រឹងការគ្រប់គ្រងឲ្យបានត្រឹមត្រូវ និងហ្មត់ចត់ និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត។

## III. រចនាសម្ព័ន្ធនៃឯកសារផែនការយុទ្ធសាស្ត្រថវិកា

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានគូសរំលេចខាងលើ បានកំណត់អំពីគោលដៅរួមនៃការប្រមូលចំណូល និងបណ្តាវិធានការចាំបាច់នានាដែលត្រូវអនុវត្ត ដើម្បីសម្រេចឲ្យបាននូវគោលដៅដែលបានដាក់ចេញនោះ ចំណែកខាងផ្នែកចំណាយវិញបានកំណត់អំពីគោលដៅរួមនៃចំណាយ និងបណ្តាអាទិភាពចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដូចនេះ ក្រសួង-ស្ថាប័ន ត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនេះ ដើម្បីឈានទៅរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួនឲ្យបានល្អ ត្រឹមត្រូវ និងមានភាពជាក់ស្តែង។ ទន្ទឹមនឹងនេះ ដើម្បីជាមូលដ្ឋានសម្រាប់ឲ្យក្រសួង-ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នា រាជរដ្ឋាភិបាលសូមកំណត់ផែនការយុទ្ធសាស្ត្រថវិកាឲ្យមានរចនាសម្ព័ន្ធ និងខ្លឹមសារដូចតទៅ ៖

**-ផ្នែកទី១:** សេចក្តីផ្តើម:

១៣-ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ត្រូវចាប់ផ្តើមដោយការរៀបរាប់អំពីតួនាទី និងបេសកកម្មចម្បងៗរបស់ក្រសួង-ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៣ និងការព្យាករសភាពការណ៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងបញ្ហាប្រឈមផ្សេងៗ ដែលត្រូវដោះស្រាយជាបន្តបន្ទាប់នៅក្នុងឆ្នាំ២០១៤ និងឆ្នាំខាងមុខ ។ បន្ទាប់មកត្រូវមានការរៀបរាប់អំពីវិធានការគោលនយោបាយសំខាន់ៗ សម្រាប់រួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ

ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី១នេះទៅតាមគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

-**ផ្នែកទី២**: គោលបំណងគោលនយោបាយ:

១៤-គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេលមធ្យមនិងវែង(៣-៥ឆ្នាំ) ដោយផ្អែកលើគោលនយោបាយតាមវិស័យដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដូចនេះ គោលបំណងគោលនយោបាយមិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំទេ។ ទោះជាយ៉ាងនេះក្តី គ្រប់ក្រសួង-ស្ថាប័នត្រូវត្រួតពិនិត្យនិងវាយតម្លៃឡើងវិញអំពីគោលបំណងគោលនយោបាយនៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤ ដែលបានផ្អែកលើយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ដើម្បីកំណត់ពីសុពលភាពនៃគោលបំណងគោលនយោបាយនោះ ដែលនាំឲ្យមានការកែសម្រួលគោលបំណងគោលនយោបាយសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ដែលត្រូវផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) ។ ទន្ទឹមនឹងនេះ ការផ្លាស់ប្តូរមុខងារ និងភារកិច្ចរបស់ស្ថាប័ន ក៏ជាកត្តាមួយដែលធ្វើឲ្យគោលបំណងគោលនយោបាយមានការផ្លាស់ប្តូរដែរ។ សូម**រៀបចំខ្លឹមសារនៃផ្នែកទី២នេះទៅតាមគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

-**ផ្នែកទី៣**: កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព:

១៥-ការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ត្រូវឲ្យឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ ព្រោះកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព គឺជាឧបករណ៍សម្រាប់អនុវត្តគោលបំណងគោលនយោបាយ។ នៅក្នុងផ្នែកនេះ គឺជាការរៀបរាប់និងពន្យល់អំពីកម្មវិធី (សម្រាប់ក្រសួងអនុវត្តថវិកាកម្មវិធី) ឬយុទ្ធសាស្ត្រអាទិភាព (សម្រាប់ក្រសួង-ស្ថាប័នដែលមិនអនុវត្តថវិកាកម្មវិធី) ដែលត្រូវបានរៀបចំឡើងដើម្បីអនុវត្តគោលបំណងគោលនយោបាយ ដែលបានកំណត់នៅក្នុងផ្នែកទី២។ កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពត្រូវមានលក្ខណៈសមាហរណកម្ម ដោយត្រូវគ្របដណ្តប់លើគម្រោងឬសកម្មភាពការងារទាំងអស់ ទាំងវាងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នត្រូវកំណត់អង្គភាពថវិកា ឬអង្គភាពប្រតិបត្តិឲ្យទទួលខុសត្រូវទៅតាមរចនាសម្ព័ន្ធកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព។ ទន្ទឹមនឹងនេះ ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ថវិកាឆ្នាំ២០១៥ ក្រសួង-ស្ថាប័ននីមួយៗត្រូវរៀបចំក្របខ័ណ្ឌច្បាស់លាស់ អំពីភារកិច្ចរបស់មន្ទីររាជធានី-ខេត្តនៅក្នុងរចនាសម្ព័ន្ធកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពរបស់ខ្លួន។ ជាទូទៅ មន្ទីររាជធានី-ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ដោយឡែកទេ ព្រោះមន្ទីរ គឺជាដៃរបស់ក្រសួងនៅតាមរាជធានី-ខេត្ត ដែលមានភារកិច្ចរួមចំណែកអនុវត្តបណ្តាកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង។ ក្រសួង-ស្ថាប័ននីមួយៗមានកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពមិនលើសពី ៥ ឡើយ ប៉ុន្តែអាចមានអនុកម្មវិធីសមស្រប និងតាមការចាំបាច់។ ក្នុងន័យនេះ មន្ទីរក៏អាចមានអនុកម្មវិធីដោយឡែកដែរ ដែលចូលរួមចំណែកសម្រេចគោលនយោបាយរួមរបស់ក្រសួងដែលបានដាក់ចេញ។ ការកំណត់កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនៃផ្នែកទី៣នេះ ក៏ត្រូវកំណត់ផងដែរ នូវតម្រូវការធនធានសម្រាប់អនុវត្ត ដែលរួមទាំងធនធានថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។ **សូមរៀបចំផ្នែកទី៣នេះតាមតារាងទី១.១ និង ១.២, និង តារាងទី២.១ និង ២.២ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

-**ផ្នែកទី៤**: សូចនាករ និងគោលដៅសូចនាករ:

១៦-គោលបំណងគោលនយោបាយ និងកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវតែមានការតាមដាននិងវាស់លទ្ធផលសម្រេចបានពីការអនុវត្តជាក់ស្តែង តាមរយៈការកំណត់សូចនាករ និងគោលដៅសូចនាករ។ នៅក្នុងការកំណត់សូចនាករ ក្រសួង-ស្ថាប័នត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងសូចនាករលទ្ធផលចុងក្រោយ។ សូចនាករលទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលអាចកំណត់គោលដៅសមិទ្ធកម្ម នៃការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រ

អាទិភាពនីមួយៗ នៅក្នុងរយៈពេលជាក់លាក់មួយ (មិនលើសពីមួយឆ្នាំ)។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលអាចកំណត់គោលដៅសមិទ្ធកម្មចុងក្រោយ ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំ នៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពក្នុងរយៈពេលមធ្យម និងវែង (លើសពីមួយឆ្នាំ)។ សូចនាករអាចមានសូចនាករបន្ថែមថ្មី និងសូចនាករចាស់ដែលត្រូវកែសម្រួល។ ការជ្រើសរើសសូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុ។ ចំពោះសូចនាករចាស់ ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ២០១៣ ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ ២០១៤ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។ កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ អាចមានសូចនាករច្រើន ប៉ុន្តែក្រសួង-ស្ថាប័នត្រូវជ្រើសរើសសូចនាករក្នុងកម្រិតមួយសមស្រប និងគ្រប់គ្រាន់ដែលធានានូវការសម្រេចបាននៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព។ ទន្ទឹមនឹងការកំណត់សូចនាករ ក្រសួង-ស្ថាប័នត្រូវកំណត់គោលដៅនៃសូចនាករ ទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះ ចាំបាច់ត្រូវឲ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណ ឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធផលនៃការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណ ឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ នៅក្នុងរយៈពេលមធ្យម និងវែង (លើសពី ១ ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុត គឺត្រូវដឹងពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះ ដែលអាចទៅកំណត់គោលដៅដែលចង់បានដើម្បីឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះ ចាំបាច់ត្រូវតែមានភាពសមស្របនិងប្រាកដនិយម ដែលអាចអនុវត្តបាន។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី៤នេះតាមតារាងទី៣.១ និង៣.២ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មក ជាមួយសារាចរណែនាំនេះ។**

-**ផ្នែកទី៥**: ការកំណត់ធនធានៈ

១៧-ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល៣ឆ្នាំ(២០១៥-២០១៧) ទៅតាមកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ **ដូចក្នុងតារាងទី៤.១និង៤.២ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយនឹងសារាចរណែនាំនេះ។** ការកំណត់ពីតម្រូវការធនធានដើម្បីអនុវត្តកម្មវិធី ឬយុទ្ធ-សាស្ត្រអាទិភាពនីមួយៗ ត្រូវផ្តោតជាសំខាន់លើកត្តាមួយចំនួនដូចខាងក្រោម៖

- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកំណត់ ជាពិសេស កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងទិសដៅសំខាន់ៗក្នុងការកំណត់អាទិភាពនៃចំណាយ។
- ការវាយតម្លៃការអនុវត្តចំណាយក្នុងរយៈកាលកន្លងមក និងការប៉ាន់ស្មានការអនុវត្តចំណាយក្នុងឆ្នាំកំពុងអនុវត្តរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត នីមួយៗ។
- ការកំណត់តម្រូវការធនធានទៅតាមឆ្នាំនីមួយៗ ត្រូវមានភាពជាក់ស្តែង និងសុក្រឹតដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ។

១៨-ការគ្រោងចំណូល គឺជាការគ្រោងចំណូលសម្រាប់រយៈពេល៣ឆ្នាំ (២០១៥-២០១៧) ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មីដែលគ្រោងនឹងដាក់ឲ្យអនុវត្ត។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលចំណូលគ្រប់ប្រភេទទាំងអស់ រួមទាំងចំណូលដែលស្ថិតក្រោមការគ្រប់គ្រង

និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តគម្រោងនៅក្នុងក្រសួង-ស្ថាប័ន **ដូចក្នុងតារាងទី៥.១និង៥.២ នៃគំរូផែនការយុទ្ធសាស្ត្រថវិកា ដែលភ្ជាប់មកជាមួយនឹង សារាចរណែនាំនេះ។** នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឲ្យរៀបចំឡើយ ប៉ុន្តែចំពោះក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលមានប្រភពចំណូល គឺត្រូវរៀបចំយុទ្ធសាស្ត្រ រួមមានទាំងគោលនយោបាយ និងវិធានការសម្រាប់ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូល។ នៅក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន ដោយរួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវផ្អែកជាសំខាន់លើ៖

- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម
- ការវាយតម្លៃការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត។

-**ផ្នែកទី៦**: សេចក្តីសន្និដ្ឋានៈ

១៩-ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ និងការលើកទិសដៅកម្មវិធីសកម្មភាព និងវិធានការ ដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ។

## IV. សេចក្តីសន្និដ្ឋាន

២០-បើគិតត្រឹមតែរយៈពេល ៥ ឆ្នាំចុងក្រោយ ពោលគឺក្នុងរយៈពេលនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ទោះបីជាបានជួបប្រទះនឹងបញ្ហាប្រឈម និងឧបសគ្គធំៗជាច្រើន ព្រះរាជាណាចក្រកម្ពុជា នៅតែអាចបោះជំហានរីកចម្រើនទៅមុខបានយ៉ាងវែង ក្នុងឋានៈជាប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់លឿននៅអាស៊ី មានការកាត់បន្ថយភាពក្រីក្របានយ៉ាងឆាប់រហ័ស និង មានគម្លាតរវាងអ្នកមាននិងអ្នកក្រកាន់តែរួមតូច។ ស្ថានភាពនេះបាននាំកម្ពុជាមកដល់ចំណុចរបត់នៃការផ្លាស់ប្តូរពីបរិមាណទៅគុណភាព ពោលគឺស្ថិតនៅលើមាត់នៃការផ្លាស់ប្តូរពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប (Low Income Status-LIS) ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប (Low Middle-Income Status - LMIS) ប្រកបដោយគុណភាព។ ប៉ុន្តែទន្ទឹមនឹងនេះ ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់ និងពិភពលោក កម្ពុជាត្រូវប្រឈមនឹងការប្រកួតប្រជែងយ៉ាងស្វិតស្វាញផងដែរ។ ប្រការនេះមានន័យថា កម្ពុជាចាំបាច់ត្រូវខិតខំថែមទៀត និងកាន់តែឲ្យបានខ្លាំងក្លាជាងមុន ពិសេសថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ត្រូវតែផ្លាស់ប្តូរឥរិយាបទ និងផ្នត់គំនិត នៅក្នុងការធ្វើការងារ ព្រមទាំងខិតខំពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន ឲ្យស្របទៅតាមនិន្នាការរបស់ពិភពលោក។ នៅក្នុងន័យនេះ ការជំរុញកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យឲ្យបានជោគជ័យ ជាពិសេស កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកត្តាស្លាប់រស់របស់កម្ពុជា។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ មិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ដែលជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ប៉ុណ្ណោះទេ ថែមទាំងសម្រាប់គាំទ្រដល់ការដ្ឋានកំណែទម្រង់ដទៃទៀត។

២១- ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដែលជាផ្នែកមួយនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាវិធានការដ៏មានសារៈសំខាន់បំផុត សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកថវិកា។ ជាវិធីសាស្ត្រជាក់ស្តែងមួយ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៥ ឲ្យបានសមស្រប ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ត្រូវត្រួតពិនិត្យឡើង

វិញនិងវាយតម្លៃលើការអនុវត្តកន្លងមក ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤ របស់ខ្លួន និងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈខាងលើ ហើយរៀបចំកែសម្រួល ទៅតាមគំរូដូចបានភ្ជាប់មកជាមួយសារាចរណែនាំនេះ។

២២-*គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០១៥ ដែលមានវិសាលភាពគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី-ខេត្ត មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យបានមុនថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៤* ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់ សម្រាប់ពិនិត្យ និងអាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តមកពិគ្រោះ និងសាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់។ ក្រសួង-ស្ថាប័នដែលមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិស្នើការវិកាជកញ្ចប់ថវិកា ដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

២៣-ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ និងឲ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឲ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឲ្យបានមុនថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត

"ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៣. សរណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំខួបអនុស្សាវរីយ៍លើកទី១២៨ នៃទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៤

ទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី១ ខែឧសភា ជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការនិងកម្មករនិយោជិតទាំងអស់ ដូចថ្ងៃបុណ្យជាតិ បុណ្យប្រពៃណី និងបុណ្យអន្តរជាតិនានាដែរ។

ដើម្បីឱ្យទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា នេះ ក្លាយជាព្រឹត្តិការណ៍ជាតិមួយដែលយើងនាំគ្នាឧទ្ទិសសម្រាប់គោលបំណងរួមរបស់យើង គឺបន្តខិតខំពង្រឹងភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ បង្កើនផលិតភាពការងារ និងគុណភាពផលិតផល ដើម្បីលើកកម្ពស់កម្រិតជីវភាពបងប្អូនកម្មករនិយោជិត រួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ ជាពិសេសការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននាឆ្នាំ២០១៥ ខាងមុខ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១២៨ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៤ មានដូចខាងក្រោម៖

១-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើជាស្ថាប័នស្នូលក្នុងការរៀបចំទិវាអន្តរជាតិនេះ ដោយ៖

- ជ្រើសរើសទីកន្លែងសមស្រប ដើម្បីរៀបចំប្រារព្ធពិធីសំណេះសំណាលថ្នាក់ជាតិ ក្រោមអធិបតីភាពរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងមានការចូលរួមពីសំណាក់តំណាងក្រសួងស្ថាប័នរដ្ឋ តំណាងស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជា តំណាងអង្គការអន្តរជាតិ តំណាងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ តំណាងអង្គការវិជ្ជាជីវៈរបស់និយោជក តំណាងអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត។

- ចេញសេចក្តីជូនដំណឹងដល់មន្ទីររាជធានី-ខេត្តក្រោមឱវាទ អង្គការវិជ្ជាជីវៈរបស់និយោជកម្ចាស់និងនាយកក្រុមហ៊ុន អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ព្រមទាំងកម្មករនិយោជិតទាំងអស់ ដើម្បីណែនាំការប្រារព្ធពិធីសំណេះសំណាលអបអរសាទរការឈប់សម្រាកតាមគោលការណ៍ និងការកំសាន្តសប្បាយតាមលទ្ធភាពរៀងៗខ្លួនរបស់សហគ្រាស គ្រឹះស្ថាន សំដៅបង្កបរិយាកាសយោគយល់គ្នារវាងកម្មករនិយោជិត និងនិយោជក ជាពិសេសចៀសវាងដាច់ខាតនូវការប្រើប្រាស់

រូបភាពទិវាពលកម្មអន្តរជាតិនេះដើម្បីធ្វើសកម្មភាពទាំងឡាយណាដែលបណ្តាលឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសង្គម។

